# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាឧទ្ធរណ៍**

## តាមនាមប្រជារាស្ត្រខ្មែរ

**សភាព្រហ្មទណ្ឌ**
**សំណុំរឿងព្រហ្មទណ្ឌ**
លេខ:៩៦៣
:ថ្ងៃទី០១-១១-២០១៣
**សាលដីកាព្រហ្មទណ្ឌ**
លេខ:៦៥ "ក្រ VI ញ"
:ថ្ងៃទី១០-៩-២០១៤

## សាលាឧទ្ធរណ៍ភ្នំពេញ

បង្កើតឡើងតាម ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ដែលប្រកាសឲ្យប្រើ តាម ព្រះរាជក្រម លេខ:នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ បានបើកសវនាការជាសាធារណៈ នៅសាលសវនាការសាលាឧទ្ធរណ៍ នាថ្ងៃទី ០៣-កញ្ញា-២០១៤ ម៉ោង៧:៣០នាទីព្រឹក ដោយមានសមាសភាពដូចតទៅ:

**សមាសភាពក្រុមប្រឹក្សាជំនុំជម្រះ**

លោក [redacted] ជាប្រធាន
លោក [redacted] ជាចៅក្រមប្រឹក្សា
លោក [redacted] ជាចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

ឯកឧត្តម [redacted] ជាអគ្គព្រះរាជអាជ្ញារង

**ក្រឡាបញ្ជីសវនាការ**

លោក [redacted]

ដើម្បីជំនុំជម្រះលើបណ្តឹងស្រូបទោសនៃរឿងក្តីព្រហ្មទណ្ឌលេខ:៩៦៣ ចុះថ្ងៃទី០១-១១-២០១៣ របស់សាលាឧទ្ធរណ៍ ដែលមាន:

-ទណ្ឌិតឈ្មោះ: [redacted] សុខា ភេទប្រុស អាយុ១៩ឆ្នាំ ជាតិខ្មែរ មុខរបរកម្មករ កើតនៅ [redacted] ឪពុកឈ្មោះ: [redacted] "រ" ម្តាយឈ្មោះ: [redacted] "រ" នៅលីវ (ចាប់ខ្លួនថ្ងៃទី២៩-៨-២០០៥, ឃុំខ្លួនថ្ងៃទី០២-៩-២០០៥) ។

មានលោក [redacted] ម៉ិច ជាមេធាវីការពារក្តីឲ្យទណ្ឌិតឈ្មោះ: [redacted] សុខា ។

-បច្ចុប្បន្នកំពុងឃុំខ្លួន នៅមណ្ឌលអប់រំកែប្រែទី១(ម១)

ទណ្ឌិតរូបនេះត្រូវបានតុលាការសម្រេចដាក់ពន្ធនាគារតាមអំណាច សាលក្រមស្ថាពរ និង សាលដីកាស្ថាពរ ចំនួន០៤ករណី រួមមានដូចខាងក្រោម៖

**ករណីទី ០១**

សំណុំរឿងព្រហ្មទណ្ឌ លេខ:១៩៩៤ ចុះថ្ងៃទី៣០-៨-២០០៥ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលមានជនជាប់ចោទ៖

-ឈ្មោះ: [redacted] សុខា ភេទប្រុស អាយុ១៩ឆ្នាំ ជាតិខ្មែរ ។

ត្រូវជាប់ចោទពីបទ: ប្លន់(លួចមានគ្នាច្រើន) ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីថ្ងៃទី២០-៦-២០០៥ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ។

-បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ:១៩២"ឋ" ចុះថ្ងៃទី២៧-១២-២០០៥ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ៖

១-ផ្តន្ទាទោសឈ្មោះ [redacted] សុខា ភេទប្រុស អាយុ១៨ឆ្នាំ ដាក់ពន្ធនាគារកំណត់ចំនួន០៥ឆ្នាំ(ប្រាំឆ្នាំ) គិតចាប់ពីថ្ងៃឃុំខ្លួន០២-៩-២០០៥ ពីបទ: ប្លន់(លួចមានគ្នាច្រើន) ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី២០-៦-២០០៥ បទល្មើសព្រហ្មទណ្ឌដែលមានចែងនិងត្រូវផ្តន្ទាទោសតាមបញ្ញត្តិមាត្រាទី៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ។

២-សាលក្រមនេះ ប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទ កំបាំងមុខជនរងគ្រោះ សម្រេចបើកផ្លូវប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

## **ករណីទី ០២**

សំណុំរឿងព្រហ្មទណ្ឌលេខ:២០១៧ ចុះថ្ងៃទី០១-៩-២០០៥ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលមានជនជាប់ចោទ៖

-ឈ្មោះ [redacted] សុខា ភេទប្រុស អាយុ១៨ឆ្នាំ ជាតិខ្មែរ ។

ត្រូវជាប់ចោទពីបទ: ប្លន់(លួចដោយមានគ្នាច្រើនគាស់ទំលុះទំលាយផ្ទះ) ប្រព្រឹត្តនៅសង្កាត់គីឡូម៉ែត្រលេខ:៦ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ កាលពីថ្ងៃទី០៥-៦-២០០៥ តាមមាត្រា៦ នៃច្បាប់ស្តីពីស្ថានទំងន់ទោសនៃបទឧក្រិដ្ឋ ។

-បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ:០៩"ច" ចុះថ្ងៃទី១១-០១-២០០៦ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ៖

១-ផ្តន្ទាទោសឈ្មោះ [redacted] សុខា ភេទប្រុស អាយុ១៨ឆ្នាំ កំណត់៥ឆ្នាំ គិតពីថ្ងៃឃុំខ្លួនថ្ងៃទី០៥-៩-២០០៥ និងឈ្មោះ [redacted] សាលឹម ភេទប្រុស អាយុ២០ឆ្នាំ កំណត់៥ឆ្នាំ គិតពីថ្ងៃចាប់ខ្លួនបានតាមដីកា ស្វែងរកចាប់ខ្លួនលេខ:៧៣៥ ចុះថ្ងៃទី២៩-១១-២០០៥ របស់ចៅក្រមស៊ើបអង្កេតនៃតុលាការក្រុងភ្នំពេញ ពីបទ ប្លន់(លួចដោយមានគ្នាច្រើនគាស់ទំលុះទំលាយផ្ទះ) ប្រព្រឹត្តនៅសង្កាត់គីឡូម៉ែត្រលេខ:៦ ខណ្ឌ ឫស្សីកែវ រាជធានីភ្នំពេញ កាលពីថ្ងៃទី០៥-៦-២០០៥ តាមមាត្រា៦ នៃច្បាប់ស្តីពីស្ថានទំងន់ទោសនៃ បទឧក្រិដ្ឋ ។

២-សាក្រមនេះជំនុំជម្រះ និង ប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទ និងមេធាវីការពារ ជនជាប់ចោទ កំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណី បើកផ្លូវប្តឹងទាស់និងប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

## **ករណីទី ០៣**

សំណុំរឿងព្រហ្មទណ្ឌ លេខ:២០១៦ ចុះថ្ងៃទី០១-៩-២០០៥ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលមានជនជាប់ចោទ៖

១-ឈ្មោះ [redacted] សុខា ភេទប្រុស អាយុ១៨ឆ្នាំ ជាតិខ្មែរ ។

២-ឈ្មោះ [redacted] ពិសិដ្ឋ ភេទប្រុស អាយុ១៨ឆ្នាំ ជាតិខ្មែរ ។

៣-ឈ្មោះ [redacted] តូវ៉ា ភេទប្រុស អាយុ២៣ឆ្នាំ ជាតិខ្មែរ ។
៤-ឈ្មោះ [redacted] វឿន ភេទប្រុស អាយុ២១ឆ្នាំ (គេចខ្លួន) ។
៥-ឈ្មោះ [redacted] ចាន់ណា ភេទប្រុស អាយុ២៣ឆ្នាំ (គេចខ្លួន) ។

ត្រូវជាប់ចោទពីបទៈ ប្លន់(លួចគាស់យកម៉ាស៊ីនត្រជាក់របស់ឈ្មោះ ឡូវ ហ៊ុយធៀម) ប្រព្រឹត្តនៅសង្កាត់គីឡូម៉ែត្រលេខ:៦ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ កាលពីថ្ងៃទី០៥-៦-២០០៥ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ។

-បានឃើញ សាលក្រមព្រហ្មទណ្ឌ លេខ:៣៦"ឆ" ចុះថ្ងៃទី២៤-៣-២០០៦ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅៈ

១-ផ្តន្ទាទោសៈ

-ឈ្មោះ [redacted] សុខា ភេទប្រុស អាយុ១៨ឆ្នាំ កើតនៅភូមិ [redacted] ទីលំនៅបច្ចុប្បន្នភូមិ [redacted] របររកស៊ីកម្មកររោងចក្រទឹកក្រូច ឪពុកឈ្មោះ [redacted] "រ" ម្តាយឈ្មោះ [redacted] "រ" នៅលីវ ទោសពីមុនគ្មាន ។ ដាក់ពន្ធនាគារ ចំនួន០៦ឆ្នាំ(ប្រាំមួយឆ្នាំ) គិតពីថ្ងៃឃុំខ្លួន(០២-៩-២០០៥) ។

-ឈ្មោះ [redacted] ពិសិដ្ឋ ភេទប្រុស អាយុ១៨ឆ្នាំ ជាតិខ្មែរ កើតនៅភូមិ [redacted] ទីលំនៅបច្ចុប្បន្នផ្ទះលេខ: [redacted] របររកស៊ីកម្មករ ឪពុកឈ្មោះ [redacted] "រ" ម្តាយឈ្មោះ [redacted] "រ" នៅលីវ ទោសពីមុនជាប់ពន្ធនាគារ៨ខែ ។

-ឈ្មោះ [redacted] វឿន ភេទប្រុស អាយុ២១ឆ្នាំ ។

-ឈ្មោះ [redacted] តូវ៉ា ភេទប្រុស អាយុ២៣ឆ្នាំ ជាតិខ្មែរ កើតនៅ [redacted] ទីលំនៅបច្ចុប្បន្នផ្ទះលេខ [redacted] របររកស៊ីមិនពិត ប្រាកដ ឪពុកឈ្មោះ [redacted] "រ" ម្តាយឈ្មោះ [redacted] "រ" នៅលីវ ទោសពីមុនគ្មាន ។

-ឈ្មោះ [redacted] ចាន់ណា ហៅ វៃ ភេទប្រុស អាយុ២០ឆ្នាំ ។

ដាក់ពន្ធនាគារម្នាក់ៗកំណត់០៦ឆ្នាំ(ប្រាំមួយឆ្នាំ) គិតពីថ្ងៃចាប់ខ្លួនបាន ។

ពីបទៈ ប្លន់(លួចគាស់យកម៉ាស៊ីនត្រជាក់របស់ឈ្មោះ [redacted] ហ៊ុយធៀម) ប្រព្រឹត្តនៅសង្កាត់គីឡូម៉ែត្រលេខ៦ ខណ្ឌឫស្សីកែវ ក្រុងភ្នំពេញ កាលពីថ្ងៃទី០៥-៦-២០០៥ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា៦នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ។

២-ទុកសិទ្ធិឲ្យជនរងគ្រោះឈ្មោះ [redacted] ហ៊ុយធៀម ប្តឹងទាមទារសំណងពីជនជាប់ចោទទាំងអស់ នៅពេលក្រោយតាមច្បាប់ ។ W-

៤៧៣

៣-សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទ [redacted] សុខា មេធាវីការពារជនជាប់ចោទលោក [redacted] តន្ទាវី កំបាំងមុខជនជាប់ចោទ [redacted] ពិសិដ្ឋ, [redacted] វឿន, [redacted] តូរ៉ា, [redacted] ចាន់ណា ហៅ វ៉ែយ ជនរងគ្រោះ [redacted] ហ៊ុយជៀម បើកផ្លូវប្ដឹងទាស់និងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

**<u>ករណីទី ០៤</u>**

សំណុំរឿងព្រហ្មទណ្ឌ លេខ:២០១៨ ចុះថ្ងៃទី០១-៩-២០០៥ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលមានជនជាប់ចោទ៖

-ឈ្មោះ [redacted] សុខា ភេទប្រុស អាយុ១៩ឆ្នាំ ជាតិខ្មែរ ។

<u>ត្រូវជាប់ចោទពីបទ:</u>ប៉ុនប៉ងប្លន់(លួចមានគ្នាច្រើន)ប្រព្រឹត្តនៅរាជធានីភ្នំពេញកាលពីថ្ងៃទី០២-៦-២០០៥ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ។

-បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ:១៣៥"ឆ" ចុះថ្ងៃទី១៣-១១-២០០៦ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ៖

១-ផ្តន្ទាទោសឈ្មោះ [redacted] សុខា ភេទប្រុស អាយុ១៨ឆ្នាំ ជាតិខ្មែរ សាសនាព្រះពុទ្ធ របររកស៊ីកម្មករ រោងចក្រទឹកកក្រូច មានទីលំនៅភូមិ [redacted] ដាក់ពន្ធនាគារកំណត់ចំនួន០៥ឆ្នាំ(ប្រាំឆ្នាំ) គិតបន្តពីសាលក្រមមុន ពីបទ:ប៉ុនប៉ងប្លន់(លួចមានគ្នាច្រើន)ប្រព្រឹត្តនៅសង្កាត់គីឡូម៉ែត្រលេខ៦ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ កាលពីថ្ងៃទី០២-៦-២០០៥ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ។

សំណុំរឿងព្រហ្មទណ្ឌ លេខ:៨៣១ ចុះថ្ងៃទី១០-៩-២០០៧ របស់សាលាឧទ្ធរណ៍ ដែលមានជនជាប់ចោទ៖

-ឈ្មោះ [redacted] សុខា ភេទប្រុស អាយុ១៩ឆ្នាំ ជាតិខ្មែរ ។

<u>ត្រូវជាប់ចោទពីបទ:</u>ប៉ុនប៉ងប្លន់(លួចមានគ្នាច្រើន)ប្រព្រឹត្តនៅរាជធានីភ្នំពេញកាលពីថ្ងៃទី០២-៦-២០០៥ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ។

-បានឃើញ សាលដីកាព្រហ្មទណ្ឌលេខ:១២០"ង" ចុះថ្ងៃទី០៣-១១-២០០៨ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ៖

១-ទទួលពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី២០-១១-២០០៦ របស់ឈ្មោះ [redacted] សុខា ទុកជាត្រឹមត្រូវ តាមទម្រង់ច្បាប់ តែបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់ ។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ:១៣៥"ឆ" ចុះថ្ងៃទី១៣-១១-២០០៦ របស់តុលាការក្រុងភ្នំពេញ ទុកជាបានការ ។

៣-បន្តឃុំខ្លួនលើឈ្មោះ [redacted] សុខាតាមមាត្រា៣៥៣និង៣៩៦ក្រមនីតិវិធីព្រហ្មទណ្ឌថ្មី។

៤-សាលដីកានេះជំនុំជម្រះ និងប្រកាសជាសាធារណៈ នៅថ្ងៃទី០៣-១១-២០០៨ ចំពោះមុខ ជនជាប់ចោទ ។ បើកផ្លូវប្តឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

-បានឃើញ របាយការណ៍រឿងព្រហ្មទណ្ឌរបស់ចៅក្រមរបាយការណ៍សភាព្រហ្មទណ្ឌ នៃសាលាឧទ្ធរណ៍ ចុះថ្ងៃទី២១-មេសា-២០១៤ ។

-បានឃើញ សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៤ ។

## នាពេលសវនាការ

-ទណ្ឌិតឈ្មោះ [redacted] សុខា (វត្តមាន)

-មេធាវី [redacted] ម៉ិច (វត្តមាន)

-ទណ្ឌិតឈ្មោះ [redacted] សុខា បានថ្លែងការណ៍ថា: ខ្លួនបានដាក់ពាក្យប្តឹងសុំស្រូបទោស ដោយហេតុថា ខ្លួនត្រូវបានតុលាការសម្រេចតាមអំណាចសាលក្រម និងសាលដីកា ចំនួន៤ បានចូលជាស្ថាពរអស់ហើយ។ នៅក្នុងពន្ធនាគារ ខ្លួនគោរពតាមបទបញ្ជាត្រឹមត្រូវអត់ដែលបង្កនូវបញ្ហាអ្វីទេ។ ខ្លួននៅក្នុងពន្ធនាគារបានរយៈពេល៩ឆ្នាំជាងហើយ ។

នៅពេលនេះ ខ្លួនសំណូមពរ សុំសាលាឧទ្ធរណ៍ស្រូបទោសឲ្យខ្លួនមកត្រឹម១០ឆ្នាំតាមច្បាប់ ។

## តំណាងមហាអយ្យការធ្វើសេចក្តីសន្និដ្ឋានថា

សំណុំរឿងសុំស្រូបទោសនេះ មានលក្ខណៈត្រឹមត្រូវតាមច្បាប់។ ចំពោះថ្ងៃឃុំខ្លួនបានសសេរដូចគ្នាដល់ទៅ៣ តាមសាលក្រម និងសាលដីកា បានបញ្ជាក់ថា អនុវត្តបន្ត ដូចនេះតាមការពិត ការអនុវត្តឃើញថា ចប់អស់ហើយ។ នៅពេលនេះការសុំស្រូបទោស ទុកជូនលោកចៅក្រមពិចារណាសម្រេចតាមច្បាប់ចុះ ។

-មេធាវី [redacted] ម៉ិច បានធ្វើសេចក្តីសន្និដ្ឋានថា: កូនក្តីខ្លួនបានដាក់ពាក្យសុំស្រូបទោសត្រឹមត្រូវតាមច្បាប់។ នៅពេលនេះ តំណាងមហាអយ្យការ បានលើកឡើងពីថ្ងៃឃុំខ្លួនឃើញថាជាផលប្រយោជន៍ដល់កូនក្តីខ្លួនផងដែរ។ ដូចនេះសំណូមពរ សុំសាលាឧទ្ធរណ៍សម្រេចស្រូបទោសឲ្យកូនក្តីខ្លួនមកត្រឹមទោស១០ឆ្នាំតាមច្បាប់ ។

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីថ្លែងការណ៍របស់ទណ្ឌិត

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវី

-ក្រោយពីបានពិនិត្យគ្រប់ឯកសារដែលពាក់ព័ន្ធ

-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## សាលាឧទ្ធរណ៍
## យល់ឃើញថា

១-ពាក្យសុំស្រូបទោសបញ្ចូលគ្នា ចុះថ្ងៃទី០៨-១០-២០១៣ របស់ទណ្ឌិតឈ្មោះ [redacted] សុខា ធ្វើឡើងត្រឹមត្រូវតាមមាត្រា៥០១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ សាលាឧទ្ធរណ៍ទទួលជំនុំជម្រះបាន។

២-ទណ្ឌិតឈ្មោះ [redacted] សុខា ត្រូវបានតុលាការសម្រេចផ្តន្ទាទោសតាមអំណាចសាលក្រម និងសាលដីកា ផ្សេងគ្នា គឺ:

+បទ ប្លន់(លួចគាស់យម៉ាស៊ីនត្រជាក់) កាលពីថ្ងៃទី០៥-៦-២០០៥ ដែលសាលក្រមស្ថាពរលេខ:៣៦"ឆ" ចុះថ្ងៃទី២៤-៣-២០០៦ របស់សាលាដំបូងរាជធានីភ្នំពេញ បានផ្តន្ទាទោសចំនួន០៦ឆ្នាំ ។

+បទ ប្លន់(លួចមានគ្នាច្រើន) កាលពីថ្ងៃទី២០-៦-២០០៥ ដែលមានសាលក្រមស្ថាពរលេខ:១៩២"ប" ចុះថ្ងៃទី២៧-១២-២០០៥ របស់សាលាដំបូងរាជធានីភ្នំពេញ បានផ្តន្ទាទោសចំនួន០៥ឆ្នាំ ។

+បទ ប្លន់(លួចមានគ្នាច្រើន) កាលពីថ្ងៃទី០៥-៦-២០០៥ ដែលមានសាលក្រមលេខ:០៩"ច" ចុះថ្ងៃទី១១-០១-២០០៦ របស់សាលាដំបូងរាជធានីភ្នំពេញ បានផ្តន្ទាទោសចំនួន០៥ឆ្នាំ ។

+បទ ប៉ុនប៉ងប្លន់(លួចមានគ្នាច្រើន) កាលពីថ្ងៃទី០២-៦-២០០៥ ដែលមានសាលដីកាព្រហ្មទណ្ឌស្ថាពរ លេខ:១២០"ង" ចុះថ្ងៃទី០៣-១១-២០០៨ របស់សាលាឧទ្ធរណ៍បានតម្កល់សាលក្រមលេខ:១៣៥"ឆ" ចុះថ្ងៃទី១៣-១១-២០០៦ របស់សាលាដំបូងរាជធានីភ្នំពេញ ផ្តន្ទាទោសចំនួន០៥ឆ្នាំ ។

៣-តំណាងមហាអយ្យការធ្វើសេចក្តីសន្និដ្ឋានថា: សំណុំរឿងសុំស្រូបទោសនេះមានលក្ខណៈត្រឹមត្រូវតាមច្បាប់។ ចំពោះថ្ងៃឃុំខ្លួនបានសសេរដូចគ្នាដល់ទៅ៣តាមសាលក្រម និងសាលដីកា បានបញ្ជាក់ថាអនុវត្តបន្ត ដូចនេះតាមការពិត ការអនុវត្តឃើញថាចប់អស់ហើយ។ នៅពេលនេះ ការសុំស្រូបទោស ទុកជូនលោកចៅក្រមពិចារណាសម្រេចតាមច្បាប់ចុះ ។

៤-មេធាវី [redacted] ម៉ាច ការពារឲ្យទណ្ឌិត បានធ្វើសេចក្តីសន្និដ្ឋានថា: កូនក្តីខ្លួនបានដាក់ពាក្យសុំស្រូបទោសត្រឹមត្រូវតាមច្បាប់។ នៅពេលនេះ តំណាងមហាអយ្យការ បានលើកឡើងពីថ្ងៃឃុំខ្លួន ឃើញថាជាផលប្រយោជន៍ដល់កូនក្តីខ្លួនផងដែរ។ ដូចនេះសំណូមពរ សុំសាលាឧទ្ធរណ៍សម្រេចស្រូបទោសឲ្យកូនក្តីខ្លួនមកត្រឹមទោស១០ឆ្នាំតាមច្បាប់ ។

៥-ទណ្ឌិតឈ្មោះ [redacted] សុខា បានធ្វើសំណូមពរនាពេលសវនាការថា: ខ្លួនបានដាក់ពាក្យប្តឹងសុំស្រូបទោស ដោយហេតុថាខ្លួនត្រូវបានតុលាការសម្រេចតាមអំណាចសាលក្រម និងសាលដីកា ចំនួន៤បានចូលជាស្ថាពរអស់ហើយ។ នៅក្នុងពន្ធនាគារ ខ្លួនគោរពតាមបទបញ្ជាត្រឹមត្រូវអត់ដែលបង្កនូវបញ្ហាអ្វីទេ។ ខ្លួននៅក្នុងពន្ធនាគារបានរយៈពេល៩ឆ្នាំជាងហើយ។ នៅពេលនេះ ខ្លួនសំណូមពរ សុំសាលាឧទ្ធរណ៍ស្រូបទោសឲ្យខ្លួនមកត្រឹម១០ឆ្នាំតាមច្បាប់ ។

៦-តាមការយល់ឃើញខាងលើ គប្បីសាលាឧទ្ធរណ៍ អនុវត្តមាត្រា១៣៨នៃក្រមព្រហ្មទណ្ឌ ដោយស្រូបទោសពន្ធនាគារទាំងអស់ ឲ្យទណ្ឌិតឈ្មោះ [redacted] សុខា ដូចខាងក្រោម:

ក-ទោសចំនួន៦ឆ្នាំនៃសាលក្រមព្រហ្មទណ្ឌស្ថាពរលេខ:៣៦"ឆ" ចុះថ្ងៃទី២៤-៣-២០០៦ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រូវស្រូបចូលទៅក្នុងទោស ចំនួន៥ឆ្នាំនៃសាលក្រមព្រហ្មទណ្ឌស្ថាពរលេខ:១៩២"ប" ចុះថ្ងៃទី២៧-១២-២០០៥ របស់សាលាដំបូងរាជធានីភ្នំពេញ ។

ខ-ទោសចំនួន៥ឆ្នាំនៃសាលក្រមព្រហ្មទណ្ឌស្ថាពរលេខៈ៩"ច" ចុះថ្ងៃទី១១-០១-២០០៦ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រូវស្រូបចូលទៅក្នុងទោស ចំនួន៥ឆ្នាំនៃសាលដីកាព្រហ្មទណ្ឌស្ថាពរលេខៈ១២០"ង" ចុះថ្ងៃទី០៣-១១-២០០៨ របស់សាលាឧទ្ធរណ៍ ។

ដូចនេះទណ្ឌិតឈ្មោះ [redacted] សុខា ត្រូវអនុវត្តទោសក្នុងពន្ធនាគារ សរុបចំនួន១០ឆ្នាំ ។

៧-ឈ្មោះ [redacted] សុខា បានឃុំខ្លួន តាំងពីថ្ងៃទី០២-៩-២០០៥ គិតមកដល់ថ្ងៃទី១០-៩-២០១៤ មានរយៈពេល០៩ឆ្នាំ០០ខែ០២ថ្ងៃហើយ ។

<u>ហេតុដូច្នេះវិនិច្ឆ័យសេចក្តី</u>

១-ទទួលបណ្តឹងស្រូបទោសចុះថ្ងៃទី០៨-១០-២០១៣របស់ទណ្ឌិតឈ្មោះ [redacted] សុខា ទុកជាត្រឹមត្រូវតាមទម្រង់និងគតិច្បាប់ ។

២-ក-ទោសចំនួន៦ឆ្នាំនៃសាលក្រមព្រហ្មទណ្ឌស្ថាពរលេខៈ៣៦"ឆ" ចុះថ្ងៃទី២៤-៣-២០០៦ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រូវស្រូបចូលទៅក្នុងទោស ចំនួន៥ឆ្នាំនៃសាលក្រមព្រហ្មទណ្ឌស្ថាពរលេខៈ១៤២"ប" ចុះថ្ងៃទី២៧-១២-២០០៥ របស់សាលាដំបូងរាជធានីភ្នំពេញ ។

ខ-ទោសចំនួន៥ឆ្នាំនៃសាលក្រមព្រហ្មទណ្ឌស្ថាពរលេខៈ៩"ច" ចុះថ្ងៃទី១១-០១-២០០៦ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រូវស្រូបចូលទៅក្នុងទោស ចំនួន៥ឆ្នាំនៃសាលដីកាព្រហ្មទណ្ឌស្ថាពរលេខៈ១២០"ង" ចុះថ្ងៃទី០៣-១១-២០០៨ របស់សាលាឧទ្ធរណ៍ ។

ដូចនេះទណ្ឌិតឈ្មោះ [redacted] សុខា ត្រូវអនុវត្តទោសក្នុងពន្ធនាគារ សរុបចំនួន១០ឆ្នាំ ។

៣-សាលដីកានេះ ប្រកាសជាសាធារណៈ នៅថ្ងៃទី១០-៩-២០១៤។ បើកផ្លូវប្តឹងសាទុក្ខតាមកំណត់ច្បាប់ ។

**សេចក្តីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកា ស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ គ្រប់តំណែង និង កងកំលាំងប្រដាប់អាវុធ ជួយសហការអនុវត្តសាលដីកានេះឲ្យបានសម្រេច ប្រសិនបើមានសំណូមពរត្រឹមត្រូវតាមច្បាប់។**

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|
| ហត្ថលេខា [redacted] | ហត្ថលេខា [redacted] | ហត្ថលេខា [redacted] |

"បានចម្លងត្រឹមត្រូវតាមច្បាប់ដើម"

ភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០១៥

ក្រឡាបញ្ជី

[redacted]

បានឃើញ

ប្រធានសាលាឧទ្ធរណ៍

[redacted]